# ពិធីសារពាក់ព័ន្ធឋានៈជនភៀសខ្លួន

ពិធីសារនេះបានទទួលការកត់សំគាល់ ដោយមានការអនុម័តយល់ព្រមពីក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច
តាមសេចក្តីសម្រេចចិត្តលេខ ១១៨៦ (XLI) ចុះថ្ងៃទី ១៨ ខែ វិច្ឆិការ ឆ្នាំ ១៩៦៦
និងបានទទួលការកត់សំគាល់ដោយមហាសន្និបាត តាមសេចក្តីសម្រេចចិត្តលេខ (XXI) ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ១៩៦៦។
តាមសេចក្តីសម្រេចចិត្តដដែលនោះ មហាសន្និបាតបានស្នើសុំអគ្គលេខាធិការ បញ្ជូនអត្ថបទពិធីសារ ទៅរដ្ឋទាំងឡាយ
ដូចបានចែងក្នុងមាត្រា ៥ ដើម្បីឱ្យរដ្ឋទាំងនោះអាចចូលជាសមាជិកនៃពិធីសារ។

ចូលជាធរមាននៅថ្ងៃទី ៤ ខែតុលា ឆ្នាំ ១៩៦៧ ដោយអនុលោមតាមមាត្រា ៨

***រដ្ឋភាគីនៃពិធីសារនេះ***

*យល់ឃើញថា* អនុសញ្ញាពាក់ព័ន្ធឋានៈជនភៀសខ្លួនអនុម័តនៅទីក្រុងហ្សឺណែវ នៅថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៥១ (ចាប់ពីនេះតទៅហៅត្រឹមថា អនុសញ្ញា) អនុវត្តតែចំពោះជនទាំងឡាយ ដែលបានក្លាយជាជនភៀសខ្លួនដោយសារព្រឹត្តិការណ៍កើតឡើងនៅមុនថ្ងៃទី ១ ខែ មករា ឆ្នាំ ១៩៥១។

*យល់ឃើញថា* ស្ថានភាពថ្មីៗនៃជនភៀសខ្លួន បានកើតឡើងចាប់តាំងពីអនុសញ្ញានេះ ត្រូវបានអនុម័ត និង*យល់ឃើញថា*ជនភៀសខ្លួនពាក់ព័ន្ធទាំងនោះ អាចនឹងមិនស្ថិតនៅក្នុងក្របខ័ណ្ឌនៃអនុសញ្ញា។

*យល់ឃើញថា* ជាសេចក្តីប្រាថ្នាចង់បានណាស់ដែលថា ជនភៀសខ្លួនទាំងអស់ត្រូវទទួលបានឋានៈស្មើៗគ្នា តាមការឱ្យនិយមន័យក្នុងអនុសញ្ញា ដោយមិនគិតអំពីកាលបរិច្ឆេទកំណត់ ថ្ងៃទី ១ ខែមករា ឆ្នាំ ១៩៥១។

***បានព្រមព្រៀងគ្នាដូចតទៅ :***

## មាត្រា ១

## បទបញ្ញត្តិទូទៅ

១. រដ្ឋភាគីនៃពិធីសារនេះ សន្យាអនុវត្តអនុសញ្ញា ចាប់តាំងពីមាត្រា ២ រហូតដល់មាត្រា ៣៤ នៃអនុសញ្ញាពាក់ព័ន្ធឋានៈនៃជនភៀស ដូចមាននិយមន័យចែងនៅក្នុងនោះ ចាប់ពីពេលនេះតទៅ។

២. សម្រាប់គោលបំណងនៃពិធីសារនេះ ពាក្យថា "ជនភៀសខ្លួន" លើកលែងតែចំពោះការអនុវត្ត ដូចមានចែងក្នុងកថាខណ្ឌ ៣ នៃមាត្រានេះចេញ និយាយសំដៅដល់ជនណាមួយ ដែលស្ថិតក្នុងនិយមន័យនៃមាត្រា ១ នៃអនុសញ្ញា ដែលហាក់ដូចពាក្យ "ដោយសារព្រឹត្តិការណ៍ ដែលបានកើតឡើងមុនថ្ងៃទី ១ មករា ១៩៥១ និង..." និង ពាក្យ "...ដោយសារព្រឹត្តិការណ៍បែបនេះ" ដែលចែងក្នុងមាត្រា ១ ក(២) ត្រូវបានលុបចោល ។

៣. ពិធីសារនេះ ត្រូវអនុវត្តតាមដោយរដ្ឋភាគី ដោយពុំមានកំណត់ភូមិសាស្ត្រណាមួយឡើយ លើកលែងតែថា សេចក្តីប្រកាសដែលមានស្រាប់ ធ្វើឡើងដោយរដ្ឋដែលជាភាគីនៃអនុសញ្ញាខាងដើម ស្របតាមមាត្រា ១ ខ(១)(ក) នៃអនុសញ្ញា បើមិនបានពង្រីកការអនុវត្តស្របតាមមាត្រា ១ ខ(២)ទេ ត្រូវតែអនុវត្តឱ្យស្របតាមពិធីសារនេះ ។

## មាត្រា ២

## សហប្រតិបត្តិការនៃអាជ្ញាធរជាតិ ជាមួយអង្គការសហប្រជាជាតិ

១. រដ្ឋភាគីនៃពិធីសារនេះ សន្យាធ្វើសហប្រតិបត្តិការ ជាមួយការិយាល័យឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន ឬជាមួយទីភ្នាក់ងារផ្សេងៗទៀត របស់អង្គការសហប្រជាជាតិ ដែលអាចបន្តកាតព្វកិច្ចពីការិយាល័យនេះ ក្នុងការអនុវត្តការងាររបស់ឧត្តមស្នងការ និងជាពិសេសជួយសម្រួលដល់ករណីយកិច្ចត្រួតពិនិត្យនៃការិយាល័យ លើការអនុវត្តបទបញ្ញត្តិនៃពិធីសារនេះ ។

២. ដើម្បីឱ្យការិយាល័យរបស់ឧត្តមស្នងការ ឬទីភ្នាក់ងាផ្សេងទៀតរបស់អង្គការសហប្រជាជាតិ ដែលអាចទទួលបន្តកាតព្វកិច្ចពីការិយាល័យនេះ អាចធ្វើរបាយការណ៍ជូនទៅស្ថាប័នមានសមត្ថកិច្ចរបស់អង្គការសហប្រជាជាតិ រដ្ឋភាគីនៃពិធីសារនេះ សន្យាផ្តល់ជូនការិយាល័យឧត្តមស្នងការ ឬទីភ្នាក់ងារនោះ នូវព័ត៌មាន និងទិន្នន័យស្ថិតិ ដែលបានស្នើសុំទាក់ទងទៅនឹងៈ

(ក) ស្ថានភាពជនភៀសខ្លួន ។

(ខ) ការអនុវត្តពិធីសារនេះ ។

(គ) ច្បាប់ បទបញ្ញត្តិ និងក្រឹត្យទាំងឡាយ ដែលនៅជាធរមាន ឬអាចចូលជាធរមានចាប់ពីពេលនេះទៅ ហើយដែលទាក់ទិននឹងជនភៀសខ្លួន ។

## មាត្រា ៣

## ព័ត៌មានស្ដីពីនីតិកម្មជាតិ

រដ្ឋភាគីនៃពិធីសារនេះ ត្រូវជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ អំពីច្បាប់ និង បទបញ្ញត្តិ ដែលរដ្ឋភាគីអាចអនុម័ត ដើម្បីធានាដល់ការអនុវត្តពិធីសារនេះ។

## មាត្រា ៤

## ការផ្សះផ្សាវិវាទ

វិវាទណាមួយរវាងរដ្ឋភាគីនៃពិធីសារនេះ ពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្ត និងមិនអាច ផ្សះផ្សារតាមមធ្យោបាយផ្សេងទៀតបាន ត្រូវបញ្ជូនទៅតុលាការយុត្តិធម៌អន្តរជាតិ តាមសេចក្ដីស្នើសុំ នៃភាគីណាមួយនៃភាគីវិវាទ។

## មាត្រា ៥

## ការចូលជាសមាជិក

ពិធីសារនេះ ត្រូវបើកឱ្យចូលជាសមាជិក ក្នុងនាមរដ្ឋភាគីទាំងអស់នៃអនុសញ្ញា និងក្នុងនាមរដ្ឋ សមាជិកផ្សេងទៀតនៃអង្គការសហប្រជាជាតិ ឬសមាជិកនៃស្ថាប័នឯកទេស ឬរដ្ឋនិងស្ថាប័ន ដែលមហា សន្និបាតអង្គការសហប្រជាជាតិ អាចអញ្ជើញឱ្យចូលជាសមាជិក។ ការចូលជាសមាជិក មានប្រសិទ្ធិភាព ដោយការតំកល់លិខិតុបករណ៍សុំចូលជាសមាជិក ជាមួយអគ្គលេខាធិការអង្គការសហប្រជាជាតិ។

## មាត្រា ៦

## បទបញ្ញត្តិស្ដីពីសហព័ន្ធ

ក្នុងករណីមានរដ្ឋសហព័ន្ធ ឬរដ្ឋមិនមែនឯកត្តរដ្ឋ បទបញ្ញត្តិខាងក្រោម ត្រូវអនុវត្ត ៖

(ក) ចំពោះមាត្រាទាំងឡាយនៃអនុសញ្ញា ដែលត្រូវអនុវត្តឱ្យស្របតាមមាត្រា ១ កថាខណ្ឌ ១ នៃពិធីសារនេះ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចច្បាប់នៃអំណាចខាងនីតិបញ្ញត្តិរបស់រដ្ឋសហព័ន្ធ កាតព្វកិច្ច របស់រដ្ឋាភិបាលសហព័ន្ធចំពោះវិសាលភាពនេះ ត្រូវដូចគ្នានឹងកាតព្វកិច្ចរបស់រដ្ឋភាគី ដែលមិនមែនជារដ្ឋ សហពន្ធ័។

(ខ) ចំពោះមាត្រាទាំងឡាយនៃអនុសញ្ញា ដែលត្រូវអនុវត្តឱ្យស្របតាមមាត្រា ១ កថាខណ្ឌ ១ នៃពិធីសារនេះ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចច្បាប់របស់រដ្ឋ ខេត្ត ឬស្រុកសមាសភាគ ដែលមិនជាប់កាតព្វកិច្ចក្នុងការចាត់វិធានការច្បាប់ ក្រោមក្របខ័ណ្ឌធម្មនុញ្ញសហព័ន្ធ រដ្ឋាភិបាលសហព័ន្ធត្រូវយកមាត្រាទាំងនោះ ជាមួយអនុសាសន៍សមស្របមួយ ជូនជាដំណឹងដល់អាជ្ញាធររដ្ឋ ខេត្ត ឬស្រុក យ៉ាងឆាប់បំផុតតាមដែលអាចធ្វើបាន។

(គ) រដ្ឋសហព័ន្ធ ដែលជាភាគីនៃពិធីសារនេះ ពេលមានសំណើរពីរដ្ឋភាគីផ្សេងណាមួយ ដែលបញ្ជូនតាមរយៈអគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវផ្តល់សេចក្តីថ្លែងការណ៍មួយអំពីច្បាប់ និងការអនុវត្តរបស់សហព័ន្ធ ព្រមទាំងផ្នែកសំខាន់ៗ ក្នុងសេចក្តីថ្លែងការណ៍ពាក់ព័ន្ធនឹងបទបញ្ញត្តិជាក់លាក់ណាមួយនៃអនុសញ្ញា ដែលត្រូវបានអនុវត្តស្របតាមមាត្រា ១ កថាខណ្ឌ ១ នៃពិធីសារនេះ ដោយបង្ហាញនូវវិសាលភាពក្នុងការផ្តល់ប្រសិទ្ធិភាពដល់បទបញ្ញត្តិនោះ តាមរយៈនីតិបញ្ញត្តិ ឬសកម្មភាពផ្សេងទៀត។

## មាត្រា ៧

## លក្ខខណ្ឌ និងសេចក្តីប្រកាស

១. នៅពេលសុំចូលជាសមាជិក រដ្ឋនីមួយៗអាចធ្វើលក្ខខណ្ឌចំពោះមាត្រា ៤ នៃពិធីសារនេះ និង ចំពោះការអនុវត្តស្របតាមមាត្រា ១ នៃពិធីសារនេះ នូវបទបញ្ញត្តិមួយចំនួននៃអនុសញ្ញា លើកលែងតែបទបញ្ញត្តិ ដែលមានចែងក្នុងមាត្រា ១ មាត្រា ៣ មាត្រា ៤ មាត្រា ១៦(១) និងមាត្រា ៣៣ នៃអនុសញ្ញា ឱ្យតែករណីដែលរដ្ឋភាគីមួយនៃអនុសញ្ញា ដែលធ្វើលក្ខខណ្ឌស្របតាមមាត្រានេះ មិនរាប់បញ្ចូលជនភៀសខ្លួន ដែលអនុសញ្ញាអនុវត្តចំពោះពួកគេ។

២. លក្ខខណ្ឌធ្វើឡើងដោយរដ្ឋភាគីនៃអនុសញ្ញាស្របតាមមាត្រា ៤២ នៃអនុសញ្ញានោះ បើមិនបានដកចេញទេ អាចអនុវត្តចំពោះកាតព្វកិច្ចរបស់រដ្ឋភាគី ស្របតាមពិធីសារនេះ។

៣. រដ្ឋណា ដែលធ្វើលក្ខខណ្ឌស្របតាមកថាខណ្ឌ ១ នៃមាត្រានេះ អាចដកលក្ខខណ្ឌនោះចេញវិញនៅពេលណាក៏បាន ដោយជូនដំណឹងអំពីការដកនោះ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។

៤. សេចក្តីប្រកាស ដែលធ្វើស្របតាមមាត្រា ៤០ កថាខណ្ឌ ១ និង ២ នៃអនុសញ្ញា ដោយរដ្ឋភាគីនៃអនុសញ្ញា ដែលសុំចូលជាសមាជិកនៃពិធីសារនេះ ត្រូវចាត់ទុកថាអនុវត្តតាមពិធីសារនេះ បើនៅពេលសុំចូលជាសមាជិក រដ្ឋភាគីពាក់ព័ន្ធពុំមានការជូនដំណឹងផ្ទុយពីនេះ ជូនអគ្គលេខាធិការអង្គការសហ

ប្រជាជាតិទេនោះ។ បទបញ្ញត្តិនៃមាត្រា ៤០ កថាខណ្ឌ ២ និង ៣ និងមាត្រា ៤៤ កថាខណ្ឌ ៣ នៃអនុសញ្ញា ត្រូវចាត់ទុកថាអនុវត្តតាមពិធីសារនេះ ក្រោយពីបានពិចារណាល្អិតល្អន់ និងកែសម្រួលជាចាំបាច់រួចហើយ។

## មាត្រា ៨

### ការចូលជាធរមាន

១. ពិធីសារនេះ ត្រូវចូលជាធរមាននៅថ្ងៃតំកល់ទុកលិខិតុបករណ៍សុំចូលជាសមាជិកទី ៦០ ។

២. ចំពោះរដ្ឋនីមួយៗ ដែលសុំចូលជាសមាជិកនៃពិធីសារ ក្រោយការតំកល់ទុកលិខិតុបករណ៍សុំចូលជាសមាជិកទី ៦០ ពិធីសារនេះចូលជាធរមាន នៅថ្ងៃតំកល់ទុកលខិតុបករណ៍សុំចូលជាសមាជិកដោយរដ្ឋនោះ។

## មាត្រា ៩

### ការប្រកាសដកខ្លួនចេញ

១. រដ្ឋភាគីណាមួយនៃពិធីសារ អាចប្រកាសដកខ្លួនចេញពីពិធីសារនេះនៅពេលណាក៏បានដោយការជូនដំណឹងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។

២. ការប្រកាសដកខ្លួនចេញបែបនេះ នឹងមានប្រសិទ្ធិភាពចំពោះរដ្ឋពាក់ព័ន្ធមួយឆ្នាំក្រោយពីថ្ងៃដែលអគ្គលេខាធិការអង្គការសហប្រជាជាតិ បានទទួលសេចក្តីប្រកាសនោះ។

## មាត្រា ១០

### ការជូនដំណឹងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ

អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនដំណឹងដល់រដ្ឋទាំងឡាយ ដូចចែងក្នុងមាត្រា ៥ ខាងលើ អំពីកាលបរិច្ឆេទចូលជាធរមាន ការសុំចូលជាសមាជិក លក្ខខណ្ឌ និងការដកចេញនូវលក្ខខណ្ឌ និងការប្រកាសដកខ្លួនចេញពីពិធីសារនេះ ព្រមទាំងសេចក្តីប្រកាស និងសេចក្តីជូនដំណឹងទាំងឡាយដែលពាក់ព័ន្ធ។

## មាត្រា ១១

### ការតំកល់ទុកក្នុងបណ្ណសារដ្ឋាននៃលេខាធិការដ្ឋានអង្គការសហប្រជាជាតិ

ឯកសារមួយច្បាប់នៃពិធីសារនេះ ដែលមានអត្ថបទសរសេរជាភាសាចិន អង់គ្លេស បារាំង រុស្ស៊ី និង អេស្ប៉ាញ៉ុល មានតម្លៃត្រឹមត្រូវតាមច្បាប់ដូចគ្នា មានចុះហត្ថលេខារបស់ប្រធានមហាសន្និបាត និង អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវដាក់តំកល់ទុកក្នុងបណ្ណសារដ្ឋាននៃលេខាធិការដ្ឋានអង្គការសហប្រជាជាតិ។ អគ្គលេខាធិការ ត្រូវបញ្ជូនច្បាប់ចម្លងមានបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើមនៃពិធីសារនេះ ទៅជូនរដ្ឋសមាជិកទាំងអស់នៃអង្គការសហប្រជាជាតិ និងរដ្ឋដទៃទៀត ដូចចែងក្នុងមាត្រា ៥ ខាងលើ។

---------//--------